**BBI0084**

# សម្ភាសន៍ជាមួយឈ្មោះ សួន ពន ភេទប្រុស អាយុ៥៦ឆ្នាំ

## មុខងារនៅសម័យខ្មែរក្រហមៈ កងចល័ត

## មុខងារបច្ចុប្បន្នៈ កសិករ

## ស្រុកកំណើតនៅភូមិខ្នែងរមាស ឃុំរោងជ្រៃ ស្រុកបាត់ដំបង ខេត្តបាត់ដំបង

## សព្វថ្ងៃរស់នៅភូមិអូរកណ្ដាល ឃុំអូររំដួល ស្រុកភ្នំព្រឹក្ស ខេត្តបាត់ដំបង

## ថ្ងៃទី២០ ខែមិនា ឆ្នាំ២០១១

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០០:៤៩:៣១

## ៣១ទំព័រ

វណ្ណៈ : ចឹងថ្ងៃនេះ ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១១ ។ ចឹងខ្ញុំសូមណែនាំខ្លួន ខ្ញុំមកពីអង្គការមជ្ឈមណ្ឌលឯកសារកម្ពុជា ។ ខ្ញុំមកក្នុងភូមិពូក៏ដើម្បីចង់ដឹងរឿងរ៉ាវប្រវត្តិភូមិ ហើយនឹងចង់ដឹង ពីអតីតកាលដែលធ្លាប់ឆ្លងកាត់ក្នុងប៉ុន្មានសម័យកន្លងមក ។ ហើយពនសម្ភាសន៍ជាមួយខ្ញុំ និងពូហ្នឹង ទុកឲ្យកូនចៅជំនាន់ក្រោយបានដឹង បានឮ ហើយនឹងបានសិក្សាស្រាវជ្រាវជា បន្តទៀត ។ ចឹងពនសម្ភាសន៍ខ្ញុំជាមួយពូ តើពូអនុញ្ញាតឲ្យឯកសារទាំងអស់នឹង ទុកឲ្យក្មេង ជំនាន់ក្រោយ យកទៅសរសេរទៅធ្វើទុកចងក្រងជាឯកសារបានទេ ពូអនុញ្ញាតទេ?

ពន : យកម៉េចយកទៅធ្វើ ។

វណ្ណៈ : បាទ! ពូមិនថាអីទេ?

ពន : បាទ!

វណ្ណៈ : ចឹងជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូៗឈ្មោះអីដែរ?

ពន : ពន ។

វណ្ណៈ : បាទ?

ពន : សួន ពន ។

វណ្ណៈ : សួន ពន ។ ពូអាយុប៉ុន្មាន?

ប្រពន្ធ : អាយុ៥៦ ។

វណ្ណៈ : ៥៦ឆ្នាំ ។ ប្រពន្ធពូឈ្មោះអីដែរ?

ប្រពន្ធ : ស សឹង ។

វណ្ណៈ : គាត់អាយុប៉ុន្មាន?

ប្រពន្ធ : ៥៧ ។

វណ្ណៈ : បងពូម៉ាឆ្នាំ?

ប្រពន្ធ : បងម៉ាឆ្នាំ ។

វណ្ណៈ : ឪពុកពូឈ្មោះអី?

ពន : ឈ្មោះ ហ៊ឹម ។

វណ្ណៈ : ត្រកូលគាត់?

ពន : ខ្ញុំអត់ចាំដែរ ។

វណ្ណៈ : ហ៊ឹម?

ពន : បាទ!

វណ្ណៈ : ម្តាយ?

ពន : ម្តាយ ឈ្មោះ រិន ។

វណ្ណៈ : ចុះគាត់ទាំងពីរសព្វថ្ងៃ?

ពន : ស្លាប់អស់រលីង ។

វណ្ណៈ : ស្លាប់ជំនាន់ណា?

ពន : ជំនាន់សម្តេច ពីជំនាន់សម្តេចសីហនុ ។

វណ្ណៈ : ចុះបងប្អូន?

ពន : ខ្ញុំមាន២នាក់ ។

វណ្ណៈ : ២នាក់នឹងសព្វថ្ងៃនៅទាំងអស់គ្នា?

ប្រពន្ធ : នៅ ។

វណ្ណៈ : ប្អូនស្រីមួយទៀតមក?

ពន : បង ។

វណ្ណៈ : បងស្រីបង?

ប្រពន្ធ : ចា៎! បង ។

វណ្ណៈ : គាត់នៅណាដែរ?

ពន : នៅខ្មែរមាស ។

វណ្ណៈ ៖ ខ្មែករមាស ។ ចឹងសព្វថ្ងៃពូមានកូនចៅប៉ុន្មាននាក់? ស

ពន ៖ កូន៤ ប្រុស២ ស្រី២ ។

វណ្ណៈ ៖ ហើយស្រុកកំណើតពូនៅភូមិអី?

ពន ៖ ស្រុកកំណើតខ្ញុំនៅខ្មែករមាសនឹងដែរ ។

វណ្ណៈ ៖ ភូមិខ្មែករមាស ភូមិ?

ពន ៖ ភូមិខ្មែករមាស ឃុំរោងជ្រៃ ពីដើម ខេត្តបាត់ដំបង ស្រុកបាត់ដំបង ខេត្តបាត់ដំបង ។

វណ្ណៈ ៖ ខ្មាចរមាស?

ពន ៖ បាទ!

វណ្ណៈ ៖ ឃុំ?

ពន ៖ ឃុំរោងជ្រៃ ។

វណ្ណៈ ៖ ឃុំរោងជ្រៃ?

ពន ៖ បាទ!

វណ្ណៈ ៖ ស្រុក?

ពន ៖ ស្រុកបាត់ដំបង ។

វណ្ណៈ ៖ ស្រុកបាត់ដំបង ខេត្តបាត់ដំបង?

ពន ៖ បាទ!

វណ្ណៈ ៖ ឥឡូវពូនៅភូមិអី?

ពន ៖ ភូមិកណ្ដាល ។

វណ្ណៈ ៖ ឃុំ?

ពន ៖ នេះឃុំអូររំដួល ។

វណ្ណៈ ៖ អូររំដួល ។ ស្រុក?

ពន ៖ ស្រុក...(ស្ដាប់មិនបាន) ។

វណ្ណៈ ៖ ខេត្ត?

ពន ៖ ខេត្តបាត់ដំបង ។

វណ្ណៈ ៖ ចឹងពូកាលពីតូច ពូរៀនបានត្រឹមថ្នាក់ណា?

ពន ៖ អត់បានរៀនផង ។

វណ្ណៈ ៖ អត់បានរៀនសោះ? មូលហេតុអីបានពូអត់បានរៀន?

ពន ៈ មូលហេតុកាលនឹងយើងនៅតូច ណាមួយម៉ែឪអត់ ។

វណ្ណៈ ៈ ម៉ែឪស្លាប់ចោល? ចឹងពូម៉ែឪស្លាប់ចោលតាំងពីពូនៅតូចៗ?

ពន ៈ នៅតូចៗ ។

វណ្ណៈ ៈ ចឹងដល់ពេលម៉ែឪស្លាប់ចោល ពូទៅនៅជាមួយពីណាគេ?

ពន ៈ ....(ស្តាប់មិនបាន) ។

វណ្ណៈ ៈ នៅជាមួយបងជួយធ្វើអីទៅ?

ពន ៈ ធ្វើស្រែតិចតួច ព្រោះមិនសូវជាផង យាមចាំ ។

វណ្ណៈ ៈ ចឹងនៅជាមួយបងធ្វើស្រែ ។ ចឹងក្រោយៗមកទៀត ដល់ពេលរដ្ឋប្រហារទម្លាក់សម្តេចសីហនុនៅឆ្នាំ៧០អី ពូទៅណាទៀត?

ពន ៈ ខ្ញុំនៅនឹងដដែល ប៉ុនចេញចូលខាងខ្មែរក្រហមនឹងហើយ ។

វណ្ណៈ ៈ ពូចេញ ឆ្នាំណាដែលពូចេញ?

ពន ៈ ខ្ញុំភ្លេចអស់ហើយ ។

វណ្ណៈ ៈ រដ្ឋប្រហារហើយបានចេញ ឬក៏?

ពន ៈ រដ្ឋប្រហារ ។

វណ្ណៈ ៈ រដ្ឋប្រហារហើយបានចូលព្រៃម៉ាគីអីចឹង?

ពន ៈ អឹ! អាចេញចូលៗ ។

វណ្ណៈ ៈ ចឹងកាលនឹងៗពូចូលដោយស្តាប់ការអំពាវនាវរបស់សម្តេចសីហនុ ឬក៏ម៉េចដែរ?

ពន ៈ កាលនឹងវាដូចតាមអំពាវនាវរបស់សម្តេចផង ។

វណ្ណៈ ៈ ចឹងពូចូលទៅ?

ពន ៈ បាទ!

វណ្ណៈ ៈ ចូលទៅតាំង៧០ ឬ៧១ ៧២?

ពន ៈ ៧១ ៧២នេះហើយ ចេញចូលៗ ។

វណ្ណៈ ៈ ចេញ កាលពូចូលៗនៅក្នុងភូមិដែលពូរស់នៅនឹង ឬក៏ចូលទៅកន្លែងតំបន់ផ្សេង?

ពន ៈ ខ្ញុំទៅនៅស្រុកខាងតាខ្ញុំ នៅស្រុកព្រៃ.... ។(ស្តាប់មិនបាន) បងប្អូនខ្ញុំនៅនឹងច្រើន ។

វណ្ណៈ ៈ ចុះចឹងទៅនៅជាមួយតាតាំងពីឆ្នាំណា?

ពន ៈ អូ! ខ្ញុំភ្លេចបាត់ហើយ ។

វណ្ណៈ ៈ ទៅនៅជាមួយតានៅ...(ស្តាប់មិនបាន) ខេត្តណា?

ពន : ស្រុកបាត់ដំបងនេះឯង ។

វណ្ណៈ : នឹងភូមិព្រៃលាវ?

ពន : បាទ!

វណ្ណៈ : បាត់ដំបងដែរ?

ពន : បាទ!

វណ្ណៈ : ពូចូលទៅអាឆ្នាំ៧១ ៧២នឹង កាលដែលពូចូលទៅនឹង មានបានវៃជាមួយពួកលន់ នល់ នៅ?

ពន : ខ្ញុំអត់បានវៃ នៅតូច គេនេះប៉ុនខ្ញុំចេញចូលៗ៣-៤ថ្ងៃចេញមកវិញមក ចេញចូលៗ ។

វណ្ណៈ : ចេញចូលទៅជួយធ្វើអីគេ?

ពន : ជួយយើងប្រាប់ដំណឹងចេញពីនឹងទៅឲ្យគេ ។

វណ្ណៈ : យើងអ្នកនាំសារ?

ពន : ...(ស្តាប់មិនបាន) ។

វណ្ណៈ : កាលចេញចូលក្នុងភូមិនៅឆ្នាំ៧១ ៧២ ៧៣នឹង កាលនឹងពូដឹងថាមានទម្លាក់គ្រាប់បែក ទេ?

ពន : ដឹងតើ ដឹង.....(ស្តាប់មិនបាន) នៅទម្លាក់ចឹង ។

វណ្ណៈ : កាលនឹងពូចូលក្នុងព្រៃហើយ ការទម្លាក់នឹង?

ពន : ចេញចូល ទៅណាទម្លាក់ បើមកនេះផុតទៅ ។

វណ្ណៈ : ចឹងនិរសាដូចថាយើង យកការណ៍ពីក្នុងទៅក្រៅពីក្រៅទៅក្នុងឲ្យខាងកងទ័ពនឹង?

ពន : បាទ!

វណ្ណៈ : ចឹងពីណាគេដឹកនាំពូនៅខាងជំនៀរបាត់ដំបងនឹង?

ពន : មេៗក្មេចឈ្មោះអស់ហើយ ។

វណ្ណៈ : ស្គាល់រស់ ញឹម រស់អីទេ?

ពន : ថីមិនស្គាល់ រស់ ញឹម តាតុំអីស្គាល់ទាំងអស់ ។

វណ្ណៈ : កាលនឹងចូលទៅជាមួយតាញឹម តាអីដែរ?

ពន : កាលនឹងតាញឹមគាត់នៅខាងតំបន់ ។

វណ្ណៈ : ហើយតាតុំ?

ពន : តាតុំគាត់ខាងតំបន់ដែរ ដល់យូរបានគាត់ឡើង តាញឹមឡើងភូមិភាគវិញ ។

វណ្ណៈ :	ចឹងកាលនឹង ការដែលពូនៅកំពុងតស៊ូក្នុងព្រៃនឹង កាលនឹងពូអត់ទាន់ស្គាល់គាញឹម តាអីស្គាល់នៅ?

ពន :	នៅ ។

វណ្ណៈ :	នៅទេនេះ ។ ដល់ពេល ចុះដល់ពេលខ្មែរក្រហមវ៉ៃបាននៅឆ្នាំ៧៥ មិនទីក្រុងភ្នំពេញ បាត់ដំបងអីចូលពេញអស់ហើយចឹង ។ ពេលដែលខ្មែរក្រហមឈ្នះហើយ គេមានបញ្ជូនពូទៅខាងណាទៀតទេ?

ពន :	ខ្ញុំអត់ ។

វណ្ណៈ :	នៅបាត់ដំបងដដែល?

ពន :	បាទ!

វណ្ណៈ :	នៅបាត់ដំបងរហូត?

ពន :	នៅបាត់ដំបង មកនៅព្រៃលាវអីនេះ ធ្វើកងចល័ត ។

វណ្ណៈ :	កងចល័ត ។ ចុះពូពេល៧៥ហើយ ម៉េចបានពូមកនៅកងចល័ត ព្រោះពូធ្លាប់ចូលជានិរសា ចូលជាអី?

ពន :	ចុះយើងចូលនៅក្រោយគេ ។

វណ្ណៈ :	ចឹងពូចូលកងចល័តវិញ៧៥?

ពន :	ធ្វើការដល់ហើយយើងចេញចូលៗ ។

វណ្ណៈ :	ពូចូលកងចល័តនៅភូមិអី?

ពន :	នៅភូមិព្រៃលាវ ។

វណ្ណៈ :	ពូធ្វើកងចល័តតាំងពី៧៥រហូតដល់ពេលណា?

ពន :	ដល់យួនចូល ។

វណ្ណៈ :	ដល់យួនចូល? កាលនឹងពូនៅជាតំបន់ប៉ុន្មាន?

ពន :	អានឹងនៅជាតំបន់៣ ។

វណ្ណៈ :	តាមពិតទៅតំបន់៣ បើពូធ្លាប់រស់នៅជាមួយប្រជាជន កងចល័តមកនៅជាមួយប្រជាជនដែរ?

ពន :	អត់ទេ ចល័តនេះចល័ត ។

វណ្ណៈ :	ចល័តអីគេ?

ពន :	ចល័តស្រុក ។

វណ្ណៈ : កងចល័តស្រុក?

ពន : បាទ! ចល័តតំបន់មានហើយ ។

វណ្ណៈ : ចឹងពូចល័តស្រុកដោយសារថា ដូចថាខ្មែរក្រហមឈ្នះហើយ លែងមានសង្គ្រាម អានឹងចល័តនឹង ប៉ុន្តែវាលក្ខណៈកងទ័ពដែរ កងទ័ពឈប់កាន់កាំភ្លើងហើយ មកចល័តវិញ ឬក៏ម៉េច?

ពន : វាចេញចូល កងទ័ពនេះ ។

វណ្ណៈ : ៧៥ ហើយ?

ពន : បាទ!

វណ្ណៈ : ចឹងអត់មាននៅជាមួយប្រជាជនទេ?

ពន : អត់ ។

វណ្ណៈ : ប្រជាជននៅដោយឡែកសហករណ៍ផ្សេងទៀត?

ពន : សហករណ៍ផ្សេងទៀត ។

វណ្ណៈ : ពូមិនមែននៅតាមសហករណ៍ទេ?

ពន : ខ្ញុំនៅប្រហែល៦-៧គីឡូពីប្រជាជន ។

វណ្ណៈ : ចឹងកងចល័តនឹងអត់នៅជាមួយបាយសហករណ៍ប្រជាជន?

ពន : បាយដោយឡែក ។

វណ្ណៈ : តាមពិតពូ នៅតំបន់៣នឹង គេថាអត់សូវលំបាកទេ ឬក៏លំបាកដែរ?

ពន : ប៉ុនកន្លែងខ្ញុំដែលវានៅដូចមិនសូវយ៉ាប់ដូច ។ ប៉ុនយ៉ាប់ថាកន្លែង...(ស្តាប់មិនបាន) ។

វណ្ណៈ : បាទ! ប៉ុន្តែនៅតំបន់៣នឹង គេថាប្រជាជនអត់សូវយ៉ាប់ដែរ តាមខ្ញុំ...(ស្តាប់មិនបាន) តាញឹក លី គាត់ប្រធានឃុំអូរដំបង ថាប្រជាជននឹងអត់សូវដែរ....ដូចថាធ្វើស្រូវបានចឹង គាត់មិនដែលរាយការណ៍ទៅអង្គការអស់ៗទេ ដូចថាបាន១០តោន គាត់ថាបាន៧តោនទេ គាត់លាក់ទុកឲ្យប្រជាជនហូបខ្លះដែរ ។ ប៉ុន្តែក្រៅពីតំបន់គាត់ ដូចជាតំបន់៤ តំបន់៥ តំបន់អីប្រជាជនស្លាប់ច្រើន ។ ប៉ុន្តែកន្លែងពូអត់អី ពូនៅកងចល័តរហូត?

ពន : ដល់យួនចូលមក បានខ្ញុំចូលព្រៃម្តងទៀត ។

វណ្ណៈ : ពូនៅកងចល័តនឹង កងចល័តៗស្រុក ក្នុងតំបន់ ពូស្គាល់ពីណាគេខ្លះ តាញឹម?

ពន : ស្គាល់បងញឹម តាតុំ ស្គាល់អីនឹង... ។

វណ្ណៈ : តាតុំគាត់ធ្វើអីដែរ?

ពន : ចល័តតំបន់ គណៈតំបន់ ។

វណ្ណៈ : ចឹងតារស់ ញឹម ហើយតាតុំ ក្រោយមកពូមានដឹងថាគាត់ទៅណា?

ពន : តាតុំគេចាប់បាត់ទៅ ។

វណ្ណៈ : ចុះតាញឹម?

ពន : គេចាប់ដែរ តាញឹមគណៈភូមិភាគ ។

វណ្ណៈ : ពូដឹងថាខាងណាគេមកចាប់ពួកគាត់ទេ?

ពន : កាលនឹងមកចាប់មានពួកមកពីខាងកើត ពួកខាងនិរតី ។

វណ្ណៈ : ការពូនៅកងចល័តនឹង គេឲ្យពូធ្វើអីខ្លះ?

ពន : ខ្ញុំគេឲ្យចូលនៅខាងសំណង់....(ស្តាប់មិនបាន) ។

វណ្ណៈ : សំណង់ ធ្វើទ្វារទឹក ធ្វើអីទៀត?

ពន : ធ្វើបាតង់តាមទន្លេបវេល ធ្វើណាណៃ ធ្វើភូមិស្ថាន ដើរធ្វើគ្រប់កន្លែង ។

វណ្ណៈ : ដើរធ្វើគ្រប់កន្លែង?

ពន : បាទ!

វណ្ណៈ : ចុះគ្នាពូប៉ុន្មាននាក់?

ពន : បាទ! ខ្ញុំធ្វើការនេះគ្នា៤០ នាក់ ។

វណ្ណៈ : អានឹងធ្វើសំណង់រហូតម៉ង់?

ពន : បាទ!

វណ្ណៈ : សំណង់បានខ្សាច់ បានស៊ីម៉ង់មកពីណា ពូដឹងកាលនឹង?

ពន : ស៊ីម៉ង់គេយកពីថ្មគោល ខ្សាច់ទៅយកពីខាងនោះបាត់ដំបង នៅម៉ាដូរស្អីគេនេះ ស៊ីម៉ង់ យើងដើរយកគ្រប់កន្លែង ពេលណាទៅយកខាងក្តុល ពេលណាទៅយកខាងស្អីខាងណា ខាងកើតអីបាត់ដំបង ។

វណ្ណៈ : ហើយកាលនឹង ដូចថាមានឡានមានអីដឹកឡាងម៉េច?

ពន : ឡានមាន គេប្រគល់ឡានឲ្យម៉ាគ្រឿង ។

វណ្ណៈ : មានឡានតែម៉ាគ្រឿងទេ ដឹកម៉េចទាន់?

ពន : ដឹកខ្សាច់ ហើយថ្មទៅយកគូសធំ ។

វណ្ណៈ : ចឹងដឹកសំណង់ ធ្វើទ្វារទឹកធ្វើអីតាមស្រុកនឹង?

ពន : បាទ!

ចម្លងចេញពី Audio ដោយៈ ហ៊ិន សុធានី-៨

វណ្ណៈ :	ហើយពេលចាប់តាញឹម តាគុំអីទៅ កន្លែងពូនឹងមានពីណាមកគ្រប់គ្រងទៀតទេ?

ពន :	ពួកមកពីនិរតី មកគ្រប់គ្រង ។

វណ្ណៈ :	អ្នកដែលមកពីនិរតីមកដូចថាកាចជាងមុន ឬក៏មិនអីទេ?

ពន :	មានខុសអីជាងមុនប៉ុន្មាន ដូចតែមុនដែរ ។

វណ្ណៈ :	ចឹងដែលមុន កាលដែលមុនពួកនិរតីមក ប្រធានកន្លែងពូពីណាគេ ប្រធានកងចល័ត?

ពន :	ប្រធានកងចល័តកាលមុនឈ្មោះ ម៉ុនដែរ ។

វណ្ណៈ :	ម៉ុន?

ពន :	បាទ!

វណ្ណៈ :	ម៉ុននឹង ក្រោយមកគេចាប់គាត់ទេ?

ពន :	គេចាប់ដែរ ។

វណ្ណៈ :	ចាប់ហើយចូលពីណាគេ?

ពន :	ចូលតាខន មកពីនិរតី ។

វណ្ណៈ :	តាខន?

ពន :	បាទ!

វណ្ណៈ :	ប៉ុន្តែពូខាងកងចល័តពូ ការហូបចុកធម្មតាទេ?

ពន :	ធម្មតា ។

វណ្ណៈ :	មិនលំបាកនេះ? ប៉ុន្តែពូដឹងថាប្រជាជនលំបាកទេ?

ពន :	ប្រជាជនយ៉ាប់ ។

វណ្ណៈ :	ហើយពូដឹងថាសម័យនឹង មានគេយកមនុស្សទៅសម្លាប់ចោល ពូដឹងទេ?

ពន :	ដឹង ក៏មិនហ៊ានមាត់ ។

វណ្ណៈ :	ចុះកាលនឹងពូភ័យដែរ ឬក៏ម៉េចដែរ?

ពន :	ភ័យដែរ ។

វណ្ណៈ :	ព្រោះពូមិនមែនអ្នកនិរតី អ្នកបាត់ដំបង?

ពន :	បាទ!

វណ្ណៈ :	ចឹងអ្នកបាត់ដំបងនៅធ្វើការជាមួយ៤០នាក់នឹង មានអ្នកណាម្នាក់ដែលគេត្រូវចាប់ខ្លួន?

ពន :	អត់មាន ។

វណ្ណៈ : អត់អីទេ កន្លែងពូអត់អីទាំងអស់ ។ ការពួកនិរតីមកគេចាប់ពួកមេៗត្រឹមណា ពូមានដឹងទេ?

ពន : គេចាប់មេៗកាលមេ គេចាប់តាំងពីមេឃុំឡើង ។

វណ្ណៈ : មេឃុំក៏ចាប់ដែរ?

ពន : បាទ!

វណ្ណៈ : ចាប់មេឃុំរហូតដល់គណៈភូមិភាគ ។ ចឹងពូដូចជាពេលចាប់តាញឹមទៅនៅឆ្នាំណា?

ពន : នឹងខ្ញុំវាមិនចាំឆ្នាំ ។

វណ្ណៈ : អត់ចាំ ។ ប៉ុន្តែពេលចាប់តាញឹមហើយ តើពីណាមកកាន់នៅភូមិភាគនឹងវិញ?

ពន : កាលនឹងខ្ញុំអត់ចាំដែរ អ្នកកាន់ភូមិភាគអ្នកមកថ្មីខ្ញុំអត់ចាំ ។

វណ្ណៈ : ចឹងដល់ពេលវៀតណាមចូលមក ពូរត់មកជាយដែនម៉ង់ ឬក៏នៅស្រុក?

ពន : ខ្ញុំរត់ទៅសំឡូត ។

វណ្ណៈ : រត់ទៅខាងសំឡូត ។ ម៉េចបានពូរត់?

ពន : ចុះយួនដេញ ។

វណ្ណៈ : ប៉ុន្តែពូរត់ៗជិតទេ រត់ពីបាត់ដំបងទៅសំឡូត វាមិនសូវឆ្ងាយ?

ពន : ដេកផ្លូវ២យប់ដែរ ។

វណ្ណៈ : ២យប់ដល់សំឡូត ។ មនុស្សច្រើនទេពូ កាលនឹង?

ពន : ទៅ៥០០-៦០០នាក់ ។

វណ្ណៈ : ចឹងម៉ាកងចល័តទៅទាំងអស់?

ពន : បាទ! កាលនឹងទៅចល័ត.......(ស្តាប់មិនបាន) ទៅនៅជុំគ្នាទាំងអស់ ។

វណ្ណៈ : ៦០០នាក់នឹងរត់តាមផ្លូវ អត់មានស្លាប់អីមានអី?

ពន : អត់មានអី ។

វណ្ណៈ : អត់មានអី ព្រោះរត់ជិត?

ពន : បាទ!

វណ្ណៈ : ហើយដឹងផ្លូវដែង ។ ប៉ុន្តែឆ្នាំ៧៩នឹង ពូថាអ្នករត់មកពីភ្នំពេញអី ជួបការលំបាកស្លាប់តាមផ្លូវ ដាច់អាហារដាច់អីកាត់ព្រៃអី មីន កាលនឹង ។

ពន : កាលនឹងខ្ញុំអត់ជួបសុខសប្បាយរហូត ។

វណ្ណៈ : ពូស្គាលផ្លូវស្គាល់អី អ្នកស្រុកបាត់ដំបងស្រាប់ចឹង វាមិនសូវមានបញ្ហាអី ។ ខ្ញុំអស់ស្គាល់ផ្លូវ ចេះខ្លាចយួនដេញ ចេះរត់ទៅកាត់ព្រៃកាត់អីក៏ដោយ ។ កាលនឹងពូទៅដល់សំឡូត ពូធ្វើអីទៀតទៅ?

ពន : ទៅដល់សំឡូត គេរៀបចំហើយបំពាក់ប្រដាប់អាវុធ ។

វណ្ណៈ : កាន់កាំភ្លើងទៀតហើយ?

ពន : បាទ!

វណ្ណៈ : កាន់កាំភ្លើងវៃជាមួយវៀតណាម?

ពន : បាទ!

វណ្ណៈ : ចឹង៧៩ម៉ង ចូលព្រៃ៧៩កាន់កាំភ្លើងទៀត?

ពន : បាទ!

វណ្ណៈ : ពីណាដឹកនាំ?

ពន : កាលនឹងតានេះ តាម៉ុក អ្នកដឹកនាំមក ទៅជួបតាម៉ុកនៅនឹងហើយ ។ តាម៉ុកចាប់ផ្ដើមបំពាក់អាវុធបំពាក់អីមក ។

វណ្ណៈ : ជួបតាម៉ុកនៅសំឡូត?

ពន : អឺ!

វណ្ណៈ : ចឹងពេលតាម៉ុកទៅអន្លង់វែង ពូទៅតាមតាម៉ុកដែរ ឬក៏អត់ទេ?

ពន : អត់ទេ អត់ទៅ ខ្ញុំនៅនឹងរបូតនឹងទៅ ។

វណ្ណៈ : នៅសំឡូតនឹងរហូត?

ពន : ចេញពីសំឡូត នៅម៉ាជួរភ្នំធំភ្នំតូចនេះ នៅវៃម៉ាជួរនឹង វៃជាមួយ ។ និយាយអាប្រវត្តិនឹង វាវែងឆ្ងាយណាស់ ។

វណ្ណៈ : ពូនិយាយមើល?

ពន : វៃចេញពីនេះ មកនៅប្រាសាទនៅវៃប្រាសាទ ។

វណ្ណៈ : ហើយម៉េចទៀត ពូនិយាយរហូតម៉ង?

ពន : វៃនៅប្រាសាទ មកនៅម៉ាជួរត្រយស្ដៅ ម៉ាជួរវត្តកោះ ថ្មគោល វៃម៉ាចំហៀងនឹង ។ ហើយបានយួនមកដល់ បាន......ចេះវៃថយក្រោយ វៃថ្មគោល បវេល ដំបូកក្នុង ម៉ាជួរ ដំបូកក្នុង គង់ ម៉ក់ហឹនអីនេះវិញ ។ យើងបានវៃជាយព្រំដែនវិញ ។

ដល់បាននឹងហើយ បានបកទៅវ៉ៃព្រៃធំនឹងវិញ តាមដងស៊ឹងម៉ាជួរបវេលជួរអីវិញ ផ្ញើសង្គ្រាមឈ្លបនឹងវិញ ។

វណ្ណៈ : ម៉េចទៀតពូ?

ពន : បេះផ្ញើសង្គ្រាមទល់រប្ញូតដល់យើងនេះបណ្ដោយ ។

វណ្ណៈ : បាទ! សមាហរណកម្មបណ្ដោយ?

ពន : បាទ!

វណ្ណៈ : ចឹងការដែលវ៉ៃជាច្រើនកន្លែងនឹង តើពូដឹងថាទាំងទាហានយួន ទាំងទាហានខ្មែរយើង ខាងខ្មែរក្រហមនឹង តើមានស្លាប់មានរបួសច្រើន?

ពន : ប៉ុនដឹងថាខាងយួនស្លាប់ច្រើនរបួស ខ្មែរក្រហមរបួស១០០នាក់អីវ៉ៃ៥នាក់ ជួនកាល១០នាក់ វ៉ៃសង្គ្រាមឈ្លប ។

វណ្ណៈ : ចឹងយួនងាប់ច្រើន?

ពន : បាទ! វ៉ៃដល់វិធីបញ្ឆោសមីន វ៉ៃដោយវិធីស្អីៗទៅ ទៅណាក៏វ៉ៃៗដុតភ្លើង ពេលយួនមកខែប្រាំង យើងវ៉ៃដុតភ្លើង យួនរាក៍យពេកវារត់ទៅ យើងដុតភ្លើងដេញតាមក្រោយ ។

វណ្ណៈ : ខ្មែរក្រហម៥នាក់ ហ៊ានវ៉ៃយួនប៉ុន្មាន ១០០នាក់អីដែរ?

ពន : បាទ! ១០នាក់ ១០០នាក់អីដាក់ម៉ាផ្លូវនេះ ។

វណ្ណៈ : ចឹងខាងខ្មែរក្រហមកាលនឹងបានអាវុធបានអីមកពីណា?

ពន : ទូតចិនៗគាំងពីខោអាវ ថ្នាំពេទ្យថ្នាំអី ។

វណ្ណៈ : សម្ភារៈចិនម៉ង ។ ចឹងកាលនឹងពូមានប្រាក់ខែកាល?

ពន : អានោះអត់ទេ ។

វណ្ណៈ : គ្មានប្រាក់ខែទេ?

ពន : គ្មានប្រាក់ខែ ។

វណ្ណៈ : វ៉ៃអត់ប្រាក់ខែម៉ង?

ពន : បាទ!

វណ្ណៈ : ហើយដល់ក្រោយមកពូឈរជើងនៅណា បានយូរជាងគេ?

ពន : ខ្ញុំនៅនេះឯង ។

វណ្ណៈ : នៅខាងណា?

ពន : ចក្រី ។

វណ្ណៈ : ចក្រីភ្នំព្រឹក្ស?

ពន : បាទ! ម៉ាជួរអស់នេះ ។

វណ្ណៈ : អត់នៅម៉ាខ្សែអីទេ?

ពន : អត់បាននៅ ។

វណ្ណៈ : ចុះនៅភ្នំព្រឹក្សនេះ ពីណាគេប្រធានកងពល?

ពន : លោក លី គិន ។

វណ្ណៈ : លី គិន?

ពន : លី គិន តាកន ឈ្មោះគេ ដាក់លី គិន ។

វណ្ណៈ : លី គិន ហៅតាកននឹង?

ពន : បាទ!

វណ្ណៈ : បើនៅខាងកំរៀង តាសុខ គង់?

ពន : តាគង់នៅក្រោមតាកននឹងដែរ ។

វណ្ណៈ : សុខ គង់ នៅក្រោមតាកនដែរ?

ពន : បាទ!

វណ្ណៈ : ចឹងតាកន គាត់ក្តាប់តាំងពីនឹងទៅ?

ពន : បាទ!

វណ្ណៈ : ចុះ សូ ហុង?

ពន : សូ ហុងនៅខាងម៉ាខ្សែ ។

វណ្ណៈ : សូ ហុងនៅខាងម៉ាខ្សែ?

ពន : បាទ!

វណ្ណៈ : ប៉ុនចឹងដល់ពេលក្តាប់រួមទាំងអស់ គណៈបញ្ជាការអី តាអៀង សារី ឬក៏មិនមែន?

ពន : តាអៀង សារីចូលមុន សុន សេនចូលមកក្រោយ ។

វណ្ណៈ : ចុះតាខៀវ សំផន?

ពន : ខៀវ សំផន គាត់ លី គិនៗយូរៗមកម្តង ។

វណ្ណៈ : ចុះខាងនេះអត់មានសម្តេចចុះមកដល់ សម្តេចសីហនុ?

ពន : អត់ដែលចុះមកដល់ទេ មានតែខៀវ សំផន ។

វណ្ណៈ : បើនៅខាងម៉ាខ្សែ សម្តេចចូលមកឆ្នាំ៨២ ។ អឺដឹងទេកាលនឹង?

ពន : ដឹង១ ៗ

វណ្ណៈ : បាទ! មានកន្លែងសារតាំង?

ពន : បាទ!

វណ្ណៈ : ចឹងកាលសម្តេចយាងចូលមកនឹង ពូបានទៅទទួលទេ?

ពន : អត់ ៗ

វណ្ណៈ : អត់១បានទៅទទួលទេ ព្រោះពូកាន់ផ្នែកខាងនេះ?

ពន : បាទ!

វណ្ណៈ : ចឹងពូកាលនឹងដូចថាដែលពូដើរច្រើនកាលជំនាន់នឹង ពូមើលឃើញថា កាលមុនមិនមែនវាលថេងចឹងទេ?

ពន : អូ! ព្រៃរាប់គីឡូដី ព្រៃដើរដេកផ្លូវម៉ោយប់អត់ផុតព្រៃ ៗ

វណ្ណៈ : ចុះពូមានដើរដាច់រ៉ូង ដូចថាភ័យវង្វេងព្រៃ វង្វេងផ្លូវ វង្វេងអី?

ពន : ខ្ញុំដើរមិនដែលវង្វេងផង ៗ

វណ្ណៈ : អត់ដែលវង្វេង?

ពន : បាទ!

វណ្ណៈ : ព្រៃនឹងសុទ្ធតែព្រៃដើមឈើធំ១ ហើយម៉េច?

ពន : ដើមឈើធំ១ ៗ

វណ្ណៈ : ដើមឈើធំ១?

ពន : សុទ្ធតែព្រៃស្មា ព្រៃទោចអីទេ ៗ

វណ្ណៈ : មានដំរីទេ?

ពន : មាន ដំរី ខ្ទីង រមាំងអីនឹង ៗ

វណ្ណៈ : ឥឡូវអស់ព្រៃអីចឹង រត់ទៅណាអស់ ដំរី ខ្លាអីនោះ ៗ

ពន : មិនបេះអស់ ខ្លានៅភ្នំនេះមានខ្លះសព្វថ្ងៃ ៗ

វណ្ណៈ : នៅលើភ្នំវាមានអីស៊ីទៅ ៗ ចុះកាលនឹងព្រៃច្រើន ពូនេះ?

ពន : បាទ!

វណ្ណៈ : ចុះពូដូចថារស់នៅពិបាកទេ កាលពូ?

ពន : យ៉ាប់ដែរ ពេលណាដាច់ដាច់ទឹកទៅដាប់ដៃ ៗ

វណ្ណៈ : ឧបមាថា ដូចទាហានខ្មែរក្រហមឈឺចាញ់អីចឹង មានពេទ្យគេមកជួយ?

ពន ៖ ពេទ្យគេមាន យើងទៅដេកពេទ្យ ។

វណ្ណៈ ៖ ចឹងគេយកទៅដេកពេទ្យ គេសែងគេអីយកទៅដេកពេទ្យ?

ពន ៖ បាទ!

វណ្ណៈ ៖ ចុះបើយើងបាញ់យួន ឧបមាថាយើងចាប់បាញ់យួនស្លាប់ចឹងតើយើងយកខ្មោចយួនមក ឬក៏អត់ទេ?

ពន ៖ អត់ដែលយកមក ។

វណ្ណៈ ៖ ទុកចោល?

ពន ៖ បាទ!

វណ្ណៈ ៖ ពួកវាមកយកវិញ?

ពន ៖ មកយកវិញ ។

វណ្ណៈ ៖ ចឹងដល់ពេលស្លាប់ចឹង យើងអត់ចាំមើលថាវាចូលមកវិញ?

ពន ៖ ពេលណាយើងចាំ ពេលណាយើងអត់ ។ យើងខ្ជិល យើងមកក្រោយ ខ្ជិលចាំ ។

វណ្ណៈ ៖ តាមធម្មតាខ្មោចវាត្រូវចូលមកយកវិញ?

ពន ៖ បាទ!

វណ្ណៈ ៖ ចុះពេលដែលខាងទាហានយួន ខាងទាហានរដ្ឋកម្ពុជាខាងនោះ ដែលចាប់បានទាហានខ្មែរក្រហមហ៎?

ពន ៖ មិនដែលសួរចាប់បានផង ។

វណ្ណៈ ៖ ចុះខាងយើងវិញចាប់បាន?

ពន ៖ ចាប់បានខ្លះដែរ ចាប់បានយួនចាប់បានអី ប៉ុនអត់ដែលសម្លាប់ផង បញ្ជូនទៅតាមជាន់ថ្នាក់នឹងទៅ ។

វណ្ណៈ ៖ បញ្ជូនទៅកងពលវិញ?

ពន ៖ បញ្ជូនទៅកងពល ៗ បញ្ជូនទៅតាមនឹងទៀត ។

វណ្ណៈ ៖ មិនសម្លាប់ទេ?

ពន ៖ អត់ទេ ។

វណ្ណៈ ៖ ចុះពូមានដែលដឹងឮថាបេះ ពេលដែលចាប់ច្រើន គ្រប់៥០នាក់ ១០០នាក់ចឹង គេយកទាហានយួនទៅដូរយកសម្ភារៈទៅដូរយកជាអង្ករ ជាអំបិលអីពីខាងថៃមកវិញ ពូមានបានឮចឹងដែរអត់? អត់ដឹងទេនេះ ពូមិនបានដឹង?

ពន : អឺ!

វណ្ណៈ : ចឹងឡូតែចាប់បានទាហានយួន យើងអត់ដែលវ៉ៃសម្លាប់អីទេ?

ពន : អត់ទេ ។

វណ្ណៈ : ដែលវ៉ៃធ្វើទារុណកម្មដែរ?

ពន : បើយើងមិនដែលនេះផង.........(ស្តាប់មិនបាន) យើងច្រើនឡូបាយហូបគ្រប់គ្រាន់ ។

វណ្ណៈ : ចឹងបញ្ជូនទៅទៀត?

ពន : បាទ!

វណ្ណៈ : ចឹងនៅពេលសម័យជំនាន់ក្រោយមកចឹង គេនៅគោរពច្បាប់សង្គ្រាមដែរតើ?

ពន : បាទ!

វណ្ណៈ : បើជំនាន់ប៉ុលពត ប្រហែលជាមិនគោរពតាមមើល ចាប់បានដឹង....។ ដល់ពេលសម័យក្រោយមក គេគោរពតាមច្បាប់សង្គ្រាម គេចាប់បានត្រូវបញ្ជូន ត្រូវរក្សាឈ្លើយសឹកអីចឹង ។ ចុះពូដោះ ដូចថាមកបោះទីតាំង ពូឈប់ធ្វើតទៅទៀត ទាហានខ្មែរក្រហមតទៅទៀត ឈប់ជាចលនាតស៊ូទៅទៀតចឹង ពូឈប់នៅឆ្នាំណា?

ពន : ឈប់ឆ្នាំដែលយើងផ្តាច់ខ្លួន ។

វណ្ណៈ : ផ្តាច់ខ្លួនសមាហរណកម្មនឹង សមាហរណកម្មនៅឆ្នាំ៩៦នឹង?

ពន : ហ្នឹង ។

វណ្ណៈ : ចឹងពូរាល់ថ្ងៃ ពូនៅបានប្រាក់បៀវត្សរសង្គមកិច្ចទេ?

ពន : អារឿងនេះ ដល់យើងផ្តាច់ខ្លួន បើយើង.....(ស្តាប់មិនបាន) គេបំបិទឈ្មោះចោល ។

វណ្ណៈ : អូ! ពូអត់ទៅរកគវ៉ា តាមពិតផ្តាច់ខ្លួនៗចូលសមាហរណកម្មនឹង មានឈ្មោះទាហាននឹងគេ អាចនៅយកប្រាក់ខែបាន យើងឈប់ជាទាហាន ប៉ុន្តែយើងអាចទទួលប្រាក់សង្គមកិច្ចសង្គមអី អ្នកខ្លះបាន ។

ពន : កាលនឹងខ្ញុំចូលនៅជាមួយគាត់ ចូលនៅកងការពារនៅគាត់ ។ ដល់ពេលផ្តាច់ខ្លួន ផ្តាច់ឈ្មោះឈឹងចឹងបណ្តោយ ។

វណ្ណៈ : អាចគេយកឈ្មោះពូបាត់ទៅ មិនដឹងទេ រឿងផ្ទៃក្នុងកន្លែងធ្វើការ ខ្ញុំមិនដឹងដែរ តែតាមធម្មតាមានឈ្មោះ មានអីចឹង ។ មកដល់ឥឡូវអ្នកខ្លះនៅទទួលប្រាក់ខែសង្គមកិច្ចបានដល់រាល់ថ្ងៃនេះ អ្នកដែលតស៊ូសម័យខ្មែរក្រហម ។ ខ្លះគេបានម៉ូតូបានអី ពូអត់ខ្លះខ្មែង ចឹងក៏

គេយកទៅ ខ្ញុំមិនដឹង ។ ចុះពូ ឪបមាថាពូមកបោះទីតាំង នៅផ្កាប់ខ្លួនហើយ ពូមកនៅណា ដាប់?

ពន : ខ្ញុំមកនៅនេះម៉ង ។

វណ្ណៈ : បើតាមពូដឹង ពូអ្នកស្រុកបាត់ដំបងដែលថា ពីដើមមកកន្លែងតំបន់នេះមានតែព្រៃ គ្មានប្រជាជនរស់នៅទេ មែនទេ?

ពន : អត់មានសុទ្ធតែព្រៃសុទ្ធ ។

វណ្ណៈ : សន្តមសីហនុៗក៏ដោយ ក៏គ្មានមនុស្សរស់នៅ?

ពន : អត់មានៗ តែផ្លូវលំ ថៅកែយ៉ូវពីដើម ។

វណ្ណៈ : ថៅកែយ៉ូវល្បីម៉េចតាំងពីម៉ាឡៃមកដល់នេះទៀត?

ពន : បាទ! មានផ្លូវថៅកែយ៉ូវពីដើម ។

វណ្ណៈ : ថៅកែយ៉ូវនឹងពីណាគេ ពូដឹងទេ?

ពន : មិនស្គាល់ដែរ មិនដែលធ្លាប់ឃើញមុខម៉េចផង ពូថាថៅកែយ៉ូវៗ ។

វណ្ណៈ : ថៅកែយ៉ូវៗ ។ ចុះពីដើមមកដូចថានៅនឹង នៅកន្លែងពូរស់នៅនឹង មានភូមិមានអីរស់នៅ ឬក៏គ្មានទេ?

ពន : អត់មានភូមិទេ ។

វណ្ណៈ : ចឹងគេហៅអី មានដឹងថាគេហៅអីពីដើម?

ពន : មានកាលនឹងខ្ញុំនៅដីថៃ...... ។

វណ្ណៈ : ចឹងអត់មានភូមិមានអីទេ?

ពន : អត់ ។

វណ្ណៈ : ហ៊ើ! ថៃណាចូលបានដល់នឹង បើសម័យខ្មែរក្រហមពាន្នាំ គេការពារព្រំដែនដែរនឹង?

ពន : អាកាលយើងសម័យសង្គ្រាម នៅក្នុងដីថៃដែរ ។

វណ្ណៈ : អូ! ចង់និយាយថាយើងៗ នៅតែដីថៃទេ ។ យើងអត់នៅនេះ?

ពន : អត់... ។

វណ្ណៈ : ម្តុំនេះអត់មានភូមិមានអីទេ?

ពន : មិនមានភូមិ ។

វណ្ណៈ : ចឹងកើតភូមិកើតអី....សម័យសមាហរណកម្មទេ?

ពន : បាទ!

វណ្ណៈ : ចឹងមានស្រុកគេហៅស្រុកភ្នំព្រឹក្ស ទើបកើត?

ពន : ទើបកើត ។

វណ្ណៈ : ពូ កាលពូធ្វើសង្គ្រាមក្រោយ៧៩នឹង បន្ទាប់ពីតាកននឹងមានពីណាធ្វើអីខ្លះ?

ពន : ចូលតានេះ សុន សេន ។

វណ្ណៈ : សុន សេនមេធំ?

ពន : សុន សេន មក ហើយគេដកតាកនចេញ សុន សេន មាស មុត តាមុតក្តាប់រូមនឹងបណ្តោយ ។

វណ្ណៈ : ចុះនៅនេះសុន សេន?

ពន : បាទ!

វណ្ណៈ : សុន សេន គាត់កាន់ប៉ុន្មាន តាំងពីកំរៀង ភ្នំព្រឹក្ស?

ពន : បាទ!

វណ្ណៈ : នៅណាទៀត?

ពន : ខាងម៉ាឡៃ ខាងអី ។ ដល់ពេលសុន សេនចូលមកនឹងចាប់ផ្តើមមានសម្លាប់ប្រជាពលរដ្ឋទៀតហើយ ។

វណ្ណៈ : ហ៎ា! ម៉េចពូថាសម្លាប់ទៀត?

ពន : ចុះ.....គាត់ផ្ទៃក្នុង ។

វណ្ណៈ : ផ្ទៃក្នុងម៉េច?

ពន : ផ្ទៃក្នុងទៅខាងជាមួយលោកហ៊ុន សែន ។ គាត់ចាប់ផ្តើមសម្លាប់ប្រជាជន អ្នកណាធ្វើខុសកាលណាធ្វើខុស យើងចាប់ដាក់គុក ដាក់អីនឹង ។

វណ្ណៈ : ចឹងនៅពេលសុន សេនចូលមកឆ្នាំណាពូចាំទេ?

ពន : ដឹងឆ្នាំអី ខ្ញុំភ្លេចអស់រលីងហើយ ។

វណ្ណៈ : ចាប់ប្រជាជន ឬក៏ចាប់ទ័ព?

ពន : ចាប់ទ័ពក៏ចាប់ ប្រជាជនក៏ចាប់ ឲ្យតែធ្វើខុស ។ ប៉ុនសុន សេនចូលមកដូចឆ្នាំ៧០ជាង៧០ប្លាយដែរនឹង ។

វណ្ណៈ : មិនមែនទេ ក្រោយ ។ សុន សេនចូលមកវាឆ្នាំ៩០ជាងហើយ ព្រោះ៧០ប្លាយនៅក្នុងសម័យខ្មែរក្រហម ។

ពន : សុន សេនចូលមកបានប៉ុន្មានឆ្នាំ សមាហរណកម្មបណ្តោយ ។

វណ្ណៈ : ចឹងសុន សេន កាច?

ពន : បាទ! ឲ្យធ្វើខុសតិចអត់បាន ដឹងចាប់ហើយ ។

វណ្ណៈ : ចឹងសុន សេនគ្រប់គ្រងតំបន់នេះ?

ពន : អឺ!

វណ្ណៈ : ចឹងខបមាថាកាលដែលសុន សេន មកគ្រប់គ្រងមានប្រមូលទ្រព្យសម្បត្តិប្រជាជនទេ?

ពន : អត់មានប្រមូលទេ គាត់ធ្វើបាបខាងផ្លូវចាស់គ្នារកស៊ីអត់បាន កាប់ចំការមិនឲ្យកាប់ ធ្វើអីមិនឲ្យកាប់ ។ ណាចាប់ប្រជាពលរដ្ឋមកពីក្នុង យកមកវៃចោលក៏មាន ។

វណ្ណៈ : ចឹងប្រជាជនមកពីក្នុង គាត់វៃចោលដែរ?

ពន : ឲ្យចាប់មកដឹងវៃចោល ប៉ុនអាអ្នកមកពីក្នុងដូចកម្រស់ដែរ គាត់ធ្វើបាប គាត់ថាសុទ្ធតែអ្នកមកស៊ើបការណ៍មកអី គាត់មិនឲ្យទុក ។

វណ្ណៈ : ចុះបើយួន?

ពន : ថាចាប់បានក៏មិនទុកដែរមើលទៅ បើថាផ្ទៃក្នុងវាម៉េចមិនដឹង អត្តភាពគាត់ជាមួយគានេ ។

វណ្ណៈ : ចឹងពូគិតថា ដោយសារអំពើឃោរឃៅរបស់សុន សេនចឹង បានជាគេសម្លាប់គ្រួសារគាត់ទាំងពូជចឹង ឬក៏ម៉េច អានឹងជាកម្មពៀរ ឬក៏យ៉ាងម៉េច បើតាមពូគិត?

ពន : កម្មពៀររបស់គាត់ ។

វណ្ណៈ : ចឹងពេលដែលសុន សេន ស្លាប់គេអរ ឬក៏ប្រជាជនអរ ឬក៏មានការអាណិត?

ពន : អត់មានអាណាអាណិតមួយទេ ។

វណ្ណៈ : ម៉េចបានចឹង?

ពន : ស្អប់គាត់ ។

វណ្ណៈ : ស្អប់គាត់?

ពន : អឺ!

វណ្ណៈ : ផុតពីរបបខ្មែរក្រហមហើយ ចូលព្រៃហើយ នៅតាមធ្វើបាបគេទៀត?

ពន : ហ្នឹង ។

វណ្ណៈ : ចុះពូមានដឹងថា រឿងសុន សេន ដែលគេសម្លាប់គាត់ទាំងគ្រួសារ ពូមានដឹងរឿងខ្លះទេ?

ពន : អានេះ.....គាត់មកនេះហើយ គាត់រត់មកនេះ គាត់រត់ចូលទៅក្នុង.........(ស្តាប់មិនបាន) ។ នៅនឹងតាម៉ុកដឹងខ្លួនទាន់ ព័ទ្ធចាប់ ។

វណ្ណៈ ៖ ចឹងរឿងរ៉ាវច្រើន នៅក្នុងសម័យខ្មែរក្រហម ក៏មានរឿងរ៉ាវសម្លាប់គ្នាឯងនឹងអ្នកធំនឹង អាចុងក្រោយមកទៀត ក៏សម្លាប់អ្នកធំគ្នាឯងតទៅទៀត ដោយការមិនទុកចិត្តគ្នា ប៊ុយ៉ាង ម៉េច?

ពន ៖ បាទ!

វណ្ណៈ ៖ ចុះប៉ុល ពត មានដែលមក?

ពន ៖ ប៉ុល ពត មិនដែលមកទេ ប៉ុននៅនេះក៏ទៅរៀនជាមួយប៉ុលពត។

វណ្ណៈ ៖ ចុះពូអត់បានចូលរួមប្រជុំជាមួយគាត់?

ពន ៖ អត់បានប្រជុំ គេប្រជុំតែវរសេនាធំ បានទៅប្រជុំជាមួយគាត់។ ហើយអ៊ីខៀវ សំផន ក៏ មិនដែលប្រជុំជាមួយ គ្រាន់ចេញជាឯកសារមក។

វណ្ណៈ ៖ ចុះពូអាចនិយាយរឿងរ៉ាវ ដែលសុន សេន ស្លាប់តិច។ ពូមានដឹងរឿងខ្លះទេ ហេតុអី?

ពន ៖ ខ្ញុំដឹងរឿងនឹង។

វណ្ណៈ ៖ ខ្ញុំមិនសូវដឹងដែរ។

ពន ៖ គាត់ថា គាត់យោរយៅ។

វណ្ណៈ ៖ ដឹងថាតាសុន សេន យោរយៅ?

ពន ៖ ប៉ុនកូនចៅគាត់ ដៃស្ដាំរបស់គាត់ អ្នកភូមិអូរល្ហុងនេះ សុទ្ធតែដៃស្ដាំគាត់។

វណ្ណៈ ៖ ចឹងនៅភូមិអូរល្ហុងជិតនេះនឹង?

ពន ៖ បាទ!

វណ្ណៈ ៖ តែកូនចៅរបៀបម៉េច?

ពន ៖ ដែល....គាត់ទុកចិត្តស្រឡាញ់។

វណ្ណៈ ៖ តែឥឡូវគេធ្វើអីដែរ?

ពន ៖ ឥឡូវគេនៅប្រជាជនធម្មតា។

វណ្ណៈ ៖ មិន អត់មានការចសាហាវ?

ពន ៖ អត់ហ៊ាន។

វណ្ណៈ ៖ ហើយប្រជាជនក៏រាប់អានគ្នាធម្មតា?

ពន ៖ រាប់អានគ្នាធម្មតា។

វណ្ណៈ ៖ ចុះពូបើសិនជាពូគិតមើល ដូចថាពូធ្លាប់ឆ្លងកាត់សម័យខ្មែរក្រហមដែរ ពូគិតថាការស្លាប់របស់ប្រជាជន និងការអត់អាហាររបស់ប្រជាជន ពូគិតថាជាការដែលអ្នកថ្នាក់លើជាអ្នកមានកំហុស ឬក៏ថ្នាក់ក្រោមជាអ្នកមានកំហុស?

ពន ៖ អានឹងមានថ្នាក់លើជាអ្នកដឹកនាំ ។

វណ្ណៈ ៖ យើងអ្នកដឹកនាំធ្វើឲ្យមានកំហុស?

ពន ៖ ហ្នឹង ។

វណ្ណៈ ៖ ដោយឲ្យប្រជាជនស្លាប់ច្រើន?

ពន ៖ ហ្នឹង ។ ដល់យើងនេះ.... បានជាប់ជាមួយហ៊ុន សែនទៅ យើងវាសុខសប្បាយរហូត ។

វណ្ណៈ ៖ ចឹងពូគិតថា ការដែលខ្មែរក្រហមមេៗប្រកាសចូលសមាហរណកម្មនឹង ដូចជាពូជាកូនទាហាននឹង ពេញចិត្តនឹងចូលដែរ ឬក៏មិនចង់ចូលទេកាលនឹង?

ពន ៖ កាលនឹង មេៗចូលហើយ កូនៗ មេៗទៅណាកូនៗទៅនឹងដែរ ។

វណ្ណៈ ៖ អត់មានជំទាស់អី?

ពន ៖ អត់មានជំទាស់ទេ ។

វណ្ណៈ ៖ ចឹងពេញចិត្តនឹងចូលដែរ?

ពន ៖ អឺ!

វណ្ណៈ ៖ ចុះដល់ពេលពូចូលហើយ ពូឃើញថាការមិនទាន់ចូល និងការដែលចូលសមាហរណកម្មនេះតើភាពរស់នៅនឹងវាមានលក្ខណៈខុសគ្នាយ៉ាងម៉េចដែរ?

ពន ៖ វាខុសគ្នា វាឈប់មានធ្វើសង្គ្រាមតទៅទៀត វាសុខសប្បាយរបូតទៅ ។

វណ្ណៈ ៖ ចឹងពូគិតថា សង្គ្រាមអាចបំផ្លាញអ្វីខ្លះដល់ប្រជាជនយើង?

ពន ៖ វាបំផ្លាញអាយុជីវិតប្រជាជនយើងអីផង ប៉ុនយើងកុំមានសង្គ្រាមតាមព្រំដែន ថៃយកអស់ដែរ ។ តាមព្រំដែន ប៉ុនៗនេះថៃយកអស់ច្រើនណាស់ដីយើង ដីខ្មែរយើង ។

វណ្ណៈ ៖ ចុះបើឥឡូវ ឧបមាថាបើសិនជាមានខ្មែរមិនត្រូវគ្នាទៀត ពូជឿថា មានអ្នកដែលចូលទៅធ្វើបដិវត្តប្រឆាំងទៀត ឬក៏មិនមាន មកដល់សម័យឥឡូវ?

ពន ៖ មិនមានទេដឹង ។

វណ្ណៈ ៖ ឥឡូវបើសិនជាចង់ចូលវាអត់មានព្រៃចូលទៀតឥឡូវនេះ ។

ពន ៖ បាទ! ចិត្តខ្ញុំសព្វថ្ងៃខ្ញុំចង់ទៅវ៉ៃថៃ ។

វណ្ណៈ ៖ តែបើសិនជាវ៉ៃខ្មែរគ្នាឯងឈប់?

ពន ៖ អឺ!

វណ្ណៈ ៖ ឈប់ហើយ បើថាទៅវីថៃ វីជាមួយបរទេសវីទៀត?

ពន ៖ អឺ! ចង់យកទឹកដីមកវិញ ។

វណ្ណៈ ៖ ចឹងយើងផ្ញើសង្គ្រាមវីខ្មែរៗគ្នាឯង រយៈពេល២០-៣០ឆ្នាំនេះ វាខាតច្រើនណាស់ ប្រទេសគេជិតខាង គេអភិវឌ្ឍន៍ អត់មានសង្គ្រាមគេជឿនលឿនដូចជា ប្រទេសថៃអីវា ក្លាយជាប្រទេសអ្នកមានអស់ហើយ ។ ហើយយើងឥឡូវទើបចាប់ផ្ដើមកសាង បើយើងកុំមានសង្គ្រាមទៅ យើងអាចអភិវឌ្ឍបានទៅមុខអីបានសុខសប្បាយដែរ ។

ពន ៖ ប៉ុនសព្វថ្ងៃវាក្ដៅដែរ រឿងថៃវាយកទឹកដីចេះចុះៗ ។

វណ្ណៈ ៖ វាដណ្ដើមប្រាសាទព្រះវិហារ ។

ពន ៖ នេះប្រាសាទព្រះវិហារ រឿងទឹកធ្លាក់នេះថៃរបស់វាដែរ ។

វណ្ណៈ ៖ ទឹកធ្លាក់?

ពន ៖ នេះនៅម៉ាភ្នំនេះ ។

វណ្ណៈ ៖ នេះជ្រលងភ្នំ?

ពន ៖ នឹងតូចនេះ វាថារបស់វាដែរ ។

វណ្ណៈ ៖ ឥឡូវយើង ឧបមាថាផ្ទះយើងនេះ ចឹងពីក្រោយផ្ទះយើងទៅប៉ុន្មានគីឡូដល់ថៃ?

ពន ៖ ព្រំដែននេះទៅប្រហែលម៉ាគីឡូជាង ។

វណ្ណៈ ៖ ម៉ាគីឡូជាងដល់ដីថៃ?

ពន ៖ បាទ!

វណ្ណៈ ៖ ចឹងប្រជាជនថៃគេដាំចំការ ដាំអីដូចគ្នាដែរ?

ពន ៖ ដាំប្រេងដូង ។

វណ្ណៈ ៖ ចឹងទៅតាមនេះមានអូរ?

ពន ៖ អូ! ប៉ុនវាចង់បានអាដីនេះ ដីកោះនេះ វាមកប៉ុន្មានសារ យើងខ្លាំងយើងដាក់វា វាអត់សូវហ៊ានដែរ ។

វណ្ណៈ ៖ ចឹងដូចថាអាអូរនឹងគេហៅអូរអី?

ពន ៖ វាហៅ គ្នាវាទឹកធ្លាក់ពីដើម ។

វណ្ណៈ ៖ អូរទឹកធ្លាក់?

ពន ៖ អានេះអូរសិប្បកម្ម អានេះគេហៅភ្នំ៥៣ ថៃចង់បានខ្លាំងណាស់អានឹង ប្រដាប់អាវុធដាក់គ្នាប៉ុន្មានសារ ។

វណ្ណៈ ៖ ចឹងអាដូចថាអាភ្នំ៥៣នឹង វានៅក្នុងខាងអូរខាងនេះ ឬអូរខាងនោះ?

ពន ៖ វានៅព្រំនឹងបណ្ដោយ អាក្រោមនេះដីកោះ ។

វណ្ណៈ ៖ ឧបមាថា អូរចឹង អូរតាមព្រំដែនចឹង វានៅអូរខាងនេះ ឬអូរខាងនោះ?

ពន ៖ វានៅចំកណ្ដាលកោះ ។

អ្នកជិតខាង ៖ ខាងនេះក៏អូរ ខាងនោះក៏អូរ ។

វណ្ណៈ ៖ វានៅពាក់កណ្ដាល ចឹងវាចង់ឲ្យយើងចែកវាដែរ?

អ្នកជិតខាង ៖ យើងអត់ធ្វើ ដីថៃក៏មិនហ៊ានធ្វើ ខ្មែរក៏មិនហ៊ានធ្វើទុកចោលនឹង ។

វណ្ណៈ ៖ គេហៅភ្នំ៥៣?

ពន ៖ បាទ!

វណ្ណៈ ៖ ម៉េចបានគេហៅភ្នំ៥៣?

ពន ៖ យើងពីដើមមកវាឈ្មោះចឹង ។

វណ្ណៈ ៖ ឮឈ្មោះតៗគ្នាមក?

ពន ៖ អឺ!

វណ្ណៈ ៖ ចុះពូអ្នក ពូគិតថាពេលឥឡូវពីមុន ឥឡូវនេះស្រួលជាង?

ពន ៖ បាទ!

វណ្ណៈ ៖ ស្រួលជាងកាលសម័យតស៊ូ?

ពន ៖ បាទ!

វណ្ណៈ ៖ ហើយប្រជាជនរស់នៅភូមិនេះ សព្វថ្ងៃមានច្រើនគ្រួសារដែរ?

ពន ៖ ច្រើន ។

វណ្ណៈ ៖ ឥឡូវអ្នកចំណូល សុទ្ធអ្នកចាស់ ឬអ្នកចំណូលថ្មីមកនៅដែរ?

ពន ៖ ឥឡូវភាគច្រើនអ្នកចំណូលថ្មី អ្នកចាស់រៀងខ្លាចខ្លះទៅនេះ ទៅនៅនោះអស់ទៅ ។

វណ្ណៈ ៖ ចុះឥឡូវដីអី ដីស្រែ ដីចំការអីថ្លៃៗដែរ?

ពន ៖ ថ្លៃដែរ ។

វណ្ណៈ ៖ ម៉ារ៉ៃប៉ុន្មាន?

ពន ៖ ម៉ារ៉ៃម៉ាម៉ឺនអី ដីភូមិម៉ារ៉ៃ៣-៤ម៉ឺន ។

វណ្ណៈ : ឥឡូវគេគិតរ៉ៃ?

ពន : បាទ!

វណ្ណៈ : ម៉ារ៉ៃនឹងប៉ុន្មានម៉ែត្រ ពូមានដឹង?

ពន : ម៉ារ៉ៃ៤០ម៉ែត្រ៤ជ្រុង របស់ខ្ញុំដីមានប៉ុន្មាន ឈឺលក់ៗ ។

វណ្ណៈ : កាលមុនពូមានប៉ុន្មានរ៉ៃដែរ?

ពន : កាលមុនមាន៣០-៤០រ៉ៃដែរ ប៉ុនឥឡូវនៅសល់ប៉ុន្មាន១៥រ៉ៃ លក់អស់រលីងរាកឈឺៗ ។

វណ្ណៈ : ឥឡូវទុក១៥រ៉ៃដាំដំឡូងដាំអីនឹង គ្រាន់ចិញ្ចឹមជីវិតតទៀត?

ពន : បាទ!

វណ្ណៈ : ឥឡូវពូមានដាំដំឡូងដាំអីទេ?

ពន : ជួលឲ្យគេ ជួលហើយអត់បានដាំខ្លួនឯង វាអត់មានដើមទុន ។

វណ្ណៈ : ជួលគេបានម៉ាឆ្នាំប៉ុន្មាន ១៥រ៉ៃនឹង?

ពន : ម៉ារ៉ៃខ្ញុំជួលគេ ម៉ារ៉ៃ៧០០ៗលុយបាត ។

វណ្ណៈ : បានថោកដែរ?

ពន : បាទ!

វណ្ណៈ : ប៉ុនគេយកទៅធ្វើទៀត មានខាត មានចំណេញ ។

ពន : ប៉ុនគេធ្វើគ្មានអីខាតដំឡូង ។

វណ្ណៈ : ដំឡូងឆ្នាំនឹងថ្លៃដង ។

ពន : ហ្នឹង ។

វណ្ណៈ : ចឹងប្រជាជនភាគច្រើននៅនឹង គេរកមុខរបររកស៊ីដាំដំឡូង ហើយដាំអីគេ?

ពន : ដាំដំឡូង ពោត សណ្តែក មុខរបរមានតែប៉ុននឹងឯង ។

វណ្ណៈ : ចុះពូដូចថា សព្វថ្ងៃនេះ ពូមានដឹងរឿងតុលាការគេកាត់ទោសមេដឹកនាំខ្មែរក្រហមធំៗ ពូមានដឹងទេ ។

ពន : អត់ដឹងផង ។

វណ្ណៈ : អត់ដឹង?

ពន : ហ្នឹង ។

វណ្ណៈ : ចុះពូអត់មានដែលស្តាប់វិទ្យុ ស្តាប់អី?

ពន ៖ មិនដែលបានស្តាប់ ។

វណ្ណៈ ៖ មិនដែលបានស្តាប់ទេ?

ពន ៖ អឺ!

វណ្ណៈ ៖ ចឹងខ្ញុំប្រាប់ថារាល់ថ្ងៃនឹង គេឃុំខ្លួនលោកតាអៀង សារី, តានួន ជា, ប្រពន្ធតាអៀង សារី, ហើយនឹងខៀវ សំផន, និងឌុច ។ តាឌុច គេកាត់ទោសហើយ ។ ចឹងនៅដល់ប៉ុន្មាននាក់ទៀត គេកាត់ទោសនិងប៉ុន្មានខែខាងមុខទៀតនឹងគេនឹងកាត់ទោសគាត់ ។ ដោយសារការដឹកនាំរបស់គាត់នឹងធ្វើឲ្យប្រជាជនស្លាប់ច្រើននៅក្នុងសម័យនឹង ។ ចឹងពូគិតថា មានតុលាការកាត់ទោសនឹង ជាការត្រឹមត្រូវ ឬក៏មិនត្រឹមត្រូវទេ បើសិនជាមតិយោបល់របស់ពូវិញ?

ពន ៖ មានទៅនេះដែលម៉េច មិនដែលបានស្តាប់រឿងនឹង ។

វណ្ណៈ ៖ តែពូគិតថាមានតុលាការជាការត្រឹមត្រូវ ឬមិនត្រឹមត្រូវទេ បើគិតពូគិត ។ មានតុលាការល្អ ឬមិនល្អ?

ពន ៖ បញ្ហាគេកាត់ទោស ត្រឹមត្រូវហើយ ។

វណ្ណៈ ៖ ហេតុអីទៅពូ បានពូគិតថាត្រឹមត្រូវ?

ពន ៖ ត្រូវរកយុត្តិធម៌ អ្នកណាខុស អ្នកណាត្រូវ ។

វណ្ណៈ ៖ ចឹងនៅក្នុងច្បាប់អន្តរជាតិអីនឹង អ្នកដឹកនាំប្រទេសមួយៗ ដែលយើងបានព្រមព្រៀងចុះហត្ថលេខានៅអង្គការសហប្រជាជាតិហើយ ការសម្លាប់មនុស្ស ការរំលោភសិទ្ធិមនុស្សនឹង វាមាននៅក្នុងច្បាប់ទាំងអស់នឹង ។ ហើយបើយើងដឹកនាំប្រទេស ស្លាប់ប្រជាជនច្រើន ទោះបីយើងមានចំណាស់ចាស់ប៉ុនណាក៏ដោយគេអត់គិតរឿងចាស់ រឿងក្មេងទេ កាល ណាដែលយើងធ្វើខុសគឺច្បាប់វិនិច្ឆ័យទោស ។ ចឹងពួកគាត់ ទោះបីគាត់ចាស់រាល់ថ្ងៃ គាត់ ចាស់ខ្លាំងណាស់ដូចតានួន ជា ៨០ជាងអីចឹង ។ ប៉ុន្តែគេមិនអាចលើកលែងទោសឲ្យគាត់ ទេ ព្រោះគាត់សម័យគាត់ដឹកនាំប្រជាជនស្លាប់ច្រើន ។ ចឹងគេត្រូវតែកាត់ទោស ។ ចឹងពូគិតថាកាត់ទោសនឹងត្រឹមត្រូវហើយ?

ពន ៖ បាទ!

វណ្ណៈ ៖ ចឹងខ្ញុំអស់សំនួរអីចង់សួរពូទៀត ពូមានអ៊ីចង់និយាយបន្ថែមទៀតទេ?

ពន ៖ ខ្ញុំអត់មានទៀតទេ ។

វណ្ណៈ ៖ ចឹងខ្ញុំអរគុណពូច្រើនៗ

ពន ៖ បាទ!

«ចប់»